00293428

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C22/5/33

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៧)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ី ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុធ្ធី

កាលបរិច្ឆេទ: ៣០ មីនា ២០០៩

---

សាធារណៈ:

## សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់លោក អៀង សារី សុំសេចក្តីបង្គាប់មួយ ឲ្យមន្ទីរពេទ្យកាល់ម៉ែត្របង្ហាញចេញជាប្រញាប់នូវកំណត់ត្រាវេជ្ជសាស្ត្រនានា និងបញ្ជីឈ្មោះគ្រូពេទ្យដែលព្យាបាល លោក អៀង សារី

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**

អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR
Elizabeth RABESANRATANA
Olivier BAHOUGNE
David BLACKMAN

**សហមេធាវីការពារក្តី**

អាង ឧត្តម
MichaelG. ARNAVAS

CERTIFIED COPY/COPIE CERTIFIÉE CONFORME
(Certified Date/Date de certification): 31 / 03 / 2009
Case File Officer/L'agent chargé du dossier: C.A. Fuy

ORIGINAL DOCUMENT/DOCUMENT ORIGINAL
(Date of receipt/Date de reception): 30 / 03 / 2009
(Time/Heure): 15:00
Case File Officer/L'agent chargé du dossier: C.A. Fuy

00293429

C22/5/33

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៧)

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") កត់សម្គាល់ឃើញ "សំណើជាបន្ទាន់របស់លោក អៀង សារី សុំសេចក្តីបង្គាប់មួយឱ្យមន្ទីរពេទ្យកាល់ម៉ែត្របង្ហាញចេញជាប្រញាប់នូវកំណត់ត្រាវេជ្ជសាស្ត្រនានា និងបញ្ជីឈ្មោះគ្រូពេទ្យដែលព្យាបាលលោក អៀង សារី" ("សំណើ") ដែលសំណើនេះត្រូវបានដាក់កាលពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៨។

## I. **ប្រវត្តិនីតិវិធី**

២. នៅក្នុងសំណើរបស់ខ្លួន សហមេធាវីការពារក្តីបានស្នើសុំដល់អង្គបុរេជំនុំជម្រះ "ឱ្យចេញសេចក្តីបង្គាប់ទៅមន្ទីរពេទ្យកាល់ម៉ែត្រឱ្យផ្តល់ព័ត៌មានដូចខាងក្រោមនេះ [...]០:

ក. "បណ្តាកំណត់ត្រាវេជ្ជសាស្ត្រទាំងអស់ដែលទាក់ទងនឹងលោក អៀង សារី ទាក់ទងនឹងការសម្រាកព្យាបាលគ្រប់លើកនៅមន្ទីរពេទ្យ និងកំណត់ត្រាប្រចាំថ្ងៃនានារបស់ លោក នេត ផល្លា។

ខ. បញ្ជីឈ្មោះគ្រូពេទ្យទាំងអស់ដែលបានព្យាបាលលោក អៀង សារី អំឡុងពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ រួមទាំងព័ត៌មានស្តីពីតួនាទីជាក់លាក់នៃគ្រូពេទ្យម្នាក់ៗនៅក្នុងការព្យាបាល លោក អៀង សារី និង

គ. ព័ត៌មានអំពីសមាជិកនានា រចនាសម្ព័ន្ធ និងអំណាចរបស់*គណៈកម្មាធិការ* ដែលជាគ្រូពេទ្យព្យាបាលទាំងអស់ ដែលមានឈ្មោះនៅក្នុងរបាយការណ៍នានារបស់មន្ទីរពេទ្យ ដែលទំនងជាអ្នកធ្វើការសម្រេចសេចក្តីសំខាន់ៗចំពោះការព្យាបាលលោក អៀង សារី"[1]។

៣. នៅក្នុងសំណើនោះ សហមេធាវីការពារក្តីបានសន្និដ្ឋានថា "លោក អៀង សារី មានសិទ្ធិផ្តាច់មុខ និងពេញទីទាំងស្រុង ដើម្បីទទួលបាននូវឯកសារនានានៃរបាយការណ៍វេជ្ជសាស្ត្ររបស់គាត់ទាំងអស់។ [លោក សារី] មានសិទ្ធិផ្តាច់មុខនិងពេញទីទាំងស្រុង ដើម្បីទទួលបាននូវព័ត៌មានទាំងឡាយស្តីពីអ្នកទាំងឡាយណាដែលកំពុងព្យាបាលគាត់ ជាពិសេស ស្តីពីអ្នកទាំងឡាយណាដែលទទួលខុស

---

[1] សំណើជាបន្ទាន់របស់លោក អៀង សារី សុំសេចក្តីបង្គាប់មួយឱ្យមន្ទីរពេទ្យកាល់ម៉ែត្រ បង្ហាញចេញជាប្រញាប់នូវកំណត់ត្រាវេជ្ជសាស្ត្រនានា និងបញ្ជីឈ្មោះគ្រូពេទ្យដែលព្យាបាលលោក អៀង សារី ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៨ C22/5/25 ("សំណើ") កថាខណ្ឌទី១ និងទី៣។

ត្រូវក្នុងការសម្រេចសេចក្តីចំពោះការព្យាបាលគាត់។ [លោក សារី] មានសិទ្ធិផ្តាច់មុខនិងពេញទីទាំងស្រុង ដើម្បីសុំឲ្យអង្គបុរេជំនុំជម្រះចេញសេចក្តីបង្គាប់មួយទៅមន្ទីរពេទ្យកាល់ម៉ែត្រ ឲ្យបង្ហាញចេញជាប្រញាប់នូវកំណត់ត្រាវេជ្ជសាស្ត្រនានា និងបញ្ជីឈ្មោះគ្រូពេទ្យ ដែលព្យាបាលគាត់ដែលជាទិន្នន័យដ៏ចាំបាច់មិនអាចចៀសផុតបានសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបន្ថែម ទាក់ទងនឹងសវនាការស្តីពីការឃុំខ្លួនបណ្តោះអាសន្ន"។

៤. សហមេធាវីការពារក្តីបានសន្និដ្ឋានថា ទោះបីជាលោក អៀង សារី ត្រូវបានគេបញ្ជូនទៅកាន់មន្ទីរពេទ្យកាល់ម៉ែត្រចំនួន១០លើក ដាច់ដោយឡែកពីគ្នាក៏ដោយ ក៏ប៉ុន្តែរបាយការណ៍វេជ្ជសាស្ត្រនៃការចូលសម្រាកព្យាបាលវិញមានចំនួនតែ៤លើកប៉ុណ្ណោះ ដែលត្រូវបានផ្តល់ ចំណែកឯរបាយការណ៍ត្រួតពិនិត្យសុខភាពប្រចាំថ្ងៃរបស់វេជ្ជបណ្ឌិតនៅអ.វ.ត.កគឺ វេជ្ជបណ្ឌិត នេត ផល្លា មិនដែលត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងឡើយ។

៥. សហមេធាវីការពារក្តីបានបន្ថែមថា ថ្វីបើសហមេធាវីការពារក្តីបានប៉ុនប៉ងទៅសួរសុខទុក្ខ លោក អៀង សារី នៅពេលដែលគាត់ត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រក៏ដោយ, ស្នើដល់វេជ្ជបណ្ឌិតអ.វ.ត.កគឺវេជ្ជបណ្ឌិត នេត ផល្លា ដើម្បីផ្តល់នូវកំណត់ត្រាវេជ្ជសាស្ត្រនានាក៏ដោយ និងមានការអះអាងពីក.ស.ច.ស ថា ជនជាប់ឃុំនៅមន្ទីរឃុំឃាំងមានសិទ្ធិទទួលបានសំណុំឯកសារយ៉ាងណាក៏ដោយ, ក៏មន្ទីរពេទ្យកាល់ម៉ែត្រនៅតែបដិសេធមិនឲ្យមានការចូលសាកសួរសុខទុក្ខ និងទទួលបានឯកសារទាំងនោះទេ។

៦. សហមេធាវីការពារក្តីបានតវ៉ាថា ដើម្បីឲ្យពួកគាត់អាចបំពេញតាមលក្ខខណ្ឌតម្រូវឲ្យបានជាក់លាក់នៅក្នុងសំណើសុំរបស់ខ្លួន ដែលបានស្នើទៅអង្គបុរេជំនុំជម្រះនោះ សហមេធាវីការពារក្តីត្រូវតែទទួលបាននូវព័ត៌មានបន្ថែមទៀតពីមន្ទីរពេទ្យកាល់ម៉ែត្រ។

៧. នៅក្នុងសេចក្តីណែនាំចេញថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានអញ្ជើញភាគីទាំងអស់ដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង ឲ្យធ្វើសេចក្តីសន្និដ្ឋានតបចំពោះសំណើ ត្រឹមថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៨[2]។

---

[2] សេចក្តីបង្គាប់ដល់ភាគីទាក់ទងនឹងសំណើជាបន្ទាន់របស់លោក អៀង សារី សុំសេចក្តីបង្គាប់មួយឲ្យមន្ទីរពេទ្យកាល់ម៉ែត្រ បង្ហាញចេញជាប្រញាប់នូវកំណត់ត្រាវេជ្ជសាស្ត្រនានា និងបញ្ជីឈ្មោះគ្រូពេទ្យដែលព្យាបាលលោក អៀង សារី C22/5/26 ... សេចក្តីសម្រេចលើសំណើរបស់លោក អៀង សារី សុំឲ្យកោះអញ្ជើញអ្នកឯកទេសវេជ្ជសាស្ត្រ

៨. នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាបានដាក់ "សេចក្តីសន្និដ្ឋានតបរបស់ខ្លួន ចំពោះសំណើរបស់លោក អៀង សារី សុំសេចក្តីបង្គាប់មួយទៅមន្ទីរពេទ្យកាល់ម៉ែត្រ ឱ្យបង្ហាញចេញជាប្រញាប់នូវកំណត់ត្រាវេជ្ជសាស្ត្រនានាព្រមទាំងព័ត៌មានផ្សេងៗទៀត" ដែលនៅក្នុងសេចក្តីសន្និដ្ឋានតបនោះ សហព្រះរាជអាជ្ញាបានស្នើដល់អង្គបុរេជំនុំជម្រះឱ្យ "ច្រានចោលពាក្យសុំនោះ"។ សហព្រះរាជអាជ្ញាបានអះអាងថា មូលហេតុដែលពួកគាត់ស្នើដល់អង្គបុរេជំនុំជម្រះឱ្យច្រានចោលពាក្យសុំនោះគឺ: ១) សំណើមិនបង្ហាញថាតើការដាក់នេះធ្វើឡើងដោយយោងតាមបទបញ្ញត្តិនៃច្បាប់ណានោះទេ។ ២) សំណើមានលក្ខណៈចម្រុះ ខ្វះភាពជាក់លាក់ និងគ្មានខ្លឹមសារផ្នែកអង្គហេតុ។ ៣) សំណើស្វែងរកឯកសារ និងការដោះស្រាយនានាដែលហួសពីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍។ ៤) សំណើមិនបានបង្ហាញអំពីមូលហេតុ ដែលដើមបណ្តឹងឧទ្ធរណ៍មិនបានប្រើអស់គ្រប់វិធីដំណោះស្រាយតាមផ្លូវច្បាប់ មុននឹងស្វែងរកវិធីដោះស្រាយតាមរយៈសហចៅក្រមស៊ើបអង្កេត និងអំពីមូលហេតុអ្វី ដែលត្រូវឱ្យអង្គជំនុំជម្រះសាលាឧទ្ធរណ៍ ដូចជាអង្គបុរេជំនុំជម្រះជាដើម ចេញសេចក្តីបង្គាប់ជាពិសេសនៅក្នុងបណ្តឹងឧទ្ធរណ៍ ដែលក្នុងនោះបញ្ហាសុខភាពរបស់ដើមបណ្តឹងឧទ្ធរណ៍មិនត្រូវបានលើកឡើងជាសំខាន់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតនោះទេ នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចបន្តថេរវេលានៃការឃុំខ្លួន ដែលជាដើមហេតុនៃបញ្ហាទាំងអស់នេះ។

៩. មកដល់ពេលនេះ ដើមបណ្តឹងរដ្ឋប្បវេណីឬក៏មេធាវីតំណាង ពុំទាន់បានដាក់ចម្លើយតបចំពោះសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះទាក់ទងនឹងសំណើសុំនៅឡើយទេ។

## II. ការពិនិត្យពិចារណា

១០. នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ នៅក្នុង "សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចដោយផ្ទាល់មាត់ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ លើសំណើ ដែលបានដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងអំឡុងពេលសវនាការដែលបានប្រព្រឹត្តទៅនៅថ្ងៃខែឆ្នាំដែល" អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញដូចខាងក្រោម:

> "សហមេធាវីការពារក្តីបានសន្និដ្ឋានថា បញ្ហាសុខភាពរបស់ជនត្រូវចោទដែលខ្លួនចង់លើកឡើង គឺជាផ្នែកមួយនៃបណ្តឹងឧទ្ធរណ៍។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បញ្ហានេះគួរលើក

ឡើងក្នុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍ទាំងមូល។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញទៀតថា នាពេលនេះ អង្គបុរេជំនុំជម្រះមិនទទួលបានសំណើបន្ថែមដែលមានលក្ខណៈជាក់លាក់ ដូចដែលអង្គបុរេជំនុំជម្រះបានលើកឡើងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ នោះទេ”[3]។

១១. សំណើមិនបានបង្ហាញនូវព័ត៌មាន “ដែលត្រូវបានស្នើ” នោះទេ ប៉ុន្តែជំនួសទៅវិញ សំណើបានស្នើដល់អង្គបុរេជំនុំជម្រះ សុំឲ្យចេញសេចក្តីបង្គាប់មួយឲ្យមន្ទីរពេទ្យកាល់ម៉ែត្រ បង្ហាញចេញជាប្រញាប់នូវព័ត៌មានដែលពាក់ព័ន្ធផ្សេងៗទៀត។

១២. ដូចដែលសហព្រះរាជអាជ្ញាបានសន្និដ្ឋានផងដែរ អង្គបុរេជំនុំជម្រះយល់ឃើញថា “[សំណើ] មិនបង្ហាញថា តើការដាក់នេះធ្វើឡើងដោយយោងតាមបទបញ្ញត្តិនៃច្បាប់ណាទេ”[4]។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់បន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតបានស្នើកាលពីខែមិថុនា និងខែកក្កដា ឆ្នាំ២០០៨ ទៅមន្ទីរពេទ្យកាល់ម៉ែត្រឲ្យអនុញ្ញាតដល់សហមេធាវីការពារក្តីបានជួបសួរសុខទុក្ខកូនក្តីរបស់ខ្លួន ខណៈពេលដែលគាត់កំពុងស្នាក់ព្យាបាលនៅក្នុងមន្ទីរពេទ្យ និងស្នើឲ្យផ្តល់ព័ត៌មានផ្នែកវេជ្ជសាស្ត្រពាក់ព័ន្ធនឹងកូនក្តីរបស់សហមេធាវីការពារក្តី ដូចដែលបានស្នើសុំដោយសហមេធាវីការពារក្តី[5]។ សំណើរបស់សហចៅក្រមស៊ើបអង្កេតនេះ នៅតែមិនទាន់មានការអនុវត្តតាមដោយមន្ទីរពេទ្យនៅឡើយទេ ដោយឡែកសហចៅក្រមស៊ើបអង្កេតក៏បានស្នើដល់ប្រធាន

---

[3] សំណៅនៃសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចដោយផ្ទាល់មាត់ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ លើសំណើ ដែលបានដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងពេលសវនាការបណ្តឹងឧទ្ធរណ៍របស់ អៀង សារី , C22/5/24 ចុះថ្ងៃ ទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩។

[4] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង សារី សុំសេចក្តីបង្គាប់ឲ្យមន្ទីរពេទ្យកាល់ម៉ែត្របង្ហាញចេញនូវកំណត់ត្រាវេជ្ជសាស្ត្រនានារបស់ អៀង សារី និងពត៏មានផ្សេងៗទៀត ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ C22/5/24,27 កថាខណ្ឌទី២។

[5] លិខិតរបស់សហចៅក្រមស៊ើបអង្កេតផ្ញើជូនប្រធានមន្ទីរពេទ្យកាល់ម៉ែត្រដែលមានកម្មវត្ថុៈ សិទ្ធិក្នុងការចូលសួរសុខទុក្ខរបស់សហមេធាវីការពារក្តីក្នុងករណីកូនក្តីត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ (A 192/II) និងចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ (A 192)។

និងអនុប្រធានការិយាល័យរដ្ឋបាល ឱ្យជួយអនុវត្តតាមសំណើប្រកបដោយប្រសិទ្ធភាពខ្ពស់ផងដែរ[6]។

១៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា វាជាកាតព្វកិច្ចរបស់សហមេធាវីការពារក្តីរបស់ជនត្រូវចោទ ក្នុងការលើកឡើងនូវបញ្ហាចោទនៅចំពោះមុខអង្គជំនុំជម្រះ។

១៤. ដូចដែលបានលើកឡើងពីខាងដើម សំណើមានលក្ខណៈហួសផុតពីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍ ហើយអង្គបុរេជំនុំជម្រះមិនមានយុត្តាធិការណាមួយ ក្រៅពីវិសាលភាពនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គជំនុំជម្រះ ដើម្បីឱ្យមានការអនុវត្តន៍តាមសំណើរបស់សហចៅក្រមស៊ើបអង្កេតនោះឡើយ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ**

**បដិសេធចោល** សំណើសុំសេចក្តីបង្គាប់មួយឱ្យមន្ទីរពេទ្យកាល់ម៉ែត្របង្ហាញចេញជាប្រញាប់នូវកំណត់ត្រាវេជ្ជសាស្ត្រនានា និងបញ្ជីឈ្មោះគ្រូពេទ្យដែលព្យាបាលលោក អៀង សារី ។

ភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩

ប្រធានអង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ប្រាក់ គីមសាន

[6] លិខិតរបស់សហចៅក្រមស៊ើបអង្កេតផ្ញើជូនប្រធាននិងអនុប្រធានការិយាល័យរដ្ឋបាលដែលមានកម្មវត្ថុ: ការជួបជាមួយកូនក្តីនៅមន្ទីរពេទ្យ ការពិគ្រោះយោបល់លើឯកសារវេជ្ជសាស្ត្រនិងបញ្ជីឈ្មោះគ្រូពេទ្យដោយមេធាវីការពារក្តី ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ (A 192/V/1) និងចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ (A 192/IV)។